01197462

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 01 / 2016
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E315/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ព័ត៌មានបន្ថែមស្តីពីសវនាការលើការបង្ហាញឯកសារគន្លឹះនៅក្នុងសំណុំរឿង ០០២/០២ និង កាលវិភាគនៃសវនាការលើការបង្ហាញឯកសារគន្លឹះលើកទីបី

១. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការអនុវត្តមួយនៅពេលធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះ ដោយផ្តល់ឱកាសឱ្យភាគីនានាដាក់បង្ហាញឯកសារគន្លឹះដែលខ្លួនយល់ឃើញថា មានការពាក់ព័ន្ធជាពិសេសទៅនឹងអង្គហេតុនីមួយៗសម្រាប់ការជំនុំជម្រះ (*សូមមើល ឧ.* ឯកសារ E170 និង ឯកសារ E288/1/1)។ សវនាការលើការបង្ហាញឯកសារគន្លឹះធ្វើឡើងដោយពិចារណាថា ឯកសារភស្តុតាងទាំងអស់មិនមែនតែងតែត្រូវបានលើកយកមកបង្ហាញនៅក្នុងអំឡុងពេលនៃការសួរដេញដោលបុគ្គលដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ហើយសវនាការនេះក៏បានផ្តល់ឱកាសដល់សាធារណជនយល់ដឹងបន្ថែមទៅលើឯកសារនានាដែលជាផ្នែកមួយនៃការជំនុំជម្រះផងដែរ។ ដោយសារមានការយល់ច្រឡំខ្លះៗកើតចេញពីសវនាការលើការបង្ហាញឯកសារគន្លឹះនាពេលកន្លងមក នាពេលនេះអង្គជំនុំជម្រះសូមរំលឹកឡើងវិញអំពីគោលការណ៍ណែនាំមុនៗរបស់ខ្លួន និង បញ្ជាក់បំភ្លឺបញ្ហាមួយចំនួននៅក្នុងអនុស្សរណៈនេះ។

***គោលការណ៍ណែនាំស្ដីពីសវនាការលើការបង្ហាញឯកសារគន្លឹះ***

២. កាលពីខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សវនាការលើការបង្ហាញឯកសារគន្លឹះនីមួយៗនឹងកម្រិតត្រឹមតែការពិភាក្សាលើឯកសារដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានជំនុំជម្រះនីមួយៗតែប៉ុណ្ណោះ (ឯកសារ E315/1)។ អង្គជំនុំជម្រះបានលើកឡើងថា នៅក្នុងអំឡុងពេលនៃសវនាការលើការបង្ហាញឯកសារគន្លឹះ ភាគីអាចយោងទៅលើឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ព្រមទាំងឯកសារទាំងឡាយដែលភាគីបានកំណត់ពីមុនថាមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ផងដែរ។ អង្គជំនុំជម្រះបានបញ្ជាក់ផងដែរថា អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីនានា និង ជនជាប់ចោទផ្ដល់យោបល់ទៅលើឯកសារដែលភាគីម្ខាងទៀតបានដាក់បង្ហាញ ប្រសិនបើពួកគេមានចេតនាក្នុងការធ្វើដូច្នេះ (ឯកសារ E315/1 កថាខណ្ឌ ៤)។ អង្គជំនុំជម្រះបានណែនាំឱ្យភាគីបញ្ជូនបញ្ជីឯកសារទាំងនោះមកអង្គជំនុំជម្រះ និង ភាគីផ្សេងទៀត មុនពេលសវនាការលើការបង្ហាញឯកសារគន្លឹះនីមួយៗចាប់ផ្ដើម ហើយគប្បីចៀសវាងការបង្ហាញឯកសារច្រំដែល ដោយមិនត្រូវជ្រើសរើសយកឯកសារទាំងឡាយណាដែលត្រូវបានពិភាក្សាលម្អិតក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីមុនរួចហើយនោះទេ (ឯកសារ E315/1 កថាខណ្ឌ ៥)។

៣. យោងតាមសារអេឡិចត្រូនិចចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ នៅមុនពេលធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះនៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងអង្គហេតុសហករណ៍ត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ ("សវនាការលើឯកសារលើកទីមួយ") អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺថា "ភាគីមានសិទ្ធិជ្រើសរើសរបៀបដែលពួកគេមានចេតនាប្រើប្រាស់ពេលវេលាដែលបានផ្ដល់ជូនឱ្យពួកគេដើម្បីធ្វើការបង្ហាញឯកសារគន្លឹះ"។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏អង្គជំនុំជម្រះបានកត់សម្គាល់ថា ការបង្ហាញឯកសារដែលជាប់ទាក់ទងផ្ទាល់នឹងអង្គហេតុដែលត្រូវជំនុំជម្រះដំបូងក្នុងសំណុំរឿង ០០២/០២ នឹងជួយដល់អង្គជំនុំជម្រះបានច្រើន ជាជាងការបង្ហាញឯកសារដែលជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុផ្សេងៗទៀត។ ក្នុងអំឡុងពេលសវនាការលើកទីមួយ ជាការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្ដី នួន ជា អង្គជំនុំជម្រះបញ្ជាក់បំភ្លឺថា សេចក្ដីដកស្រង់ចេញពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និង កំណត់ហេតុស្ដាប់ចម្លើយ អាចបង្ហាញជូនបាន (ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៤៧-៤៩)។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបាន

ដាក់បញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង កំណត់ហេតុស្តាប់ចម្លើយមួយនៅក្នុងការដាក់បង្ហាញឯកសាររបស់ខ្លួន។ ចំណែកមេធាវីការពារក្តី នួន ជា បានបញ្ចូលកំណត់ហេតុស្តាប់ចម្លើយមួយនៅក្នុងការបង្ហាញរបស់ខ្លួនដែរ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៤៩, ៥៧-៥៨, ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៣)។ ក្នុងអំឡុងសវនាការលើកទីមួយផងដែរ អង្គជំនុំជម្រះបានសម្រេចថា ភាគីនានា ក្នុងនោះរួមមានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារក្តី ខៀវ សំផន មិនអាចបង្ហាញឯកសារដែលពាក់ព័ន្ធតែចំពោះគោលនយោបាយនៅត្រឹមកម្រិតថ្នាក់ជាតិតែប៉ុណ្ណោះនោះទេ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៣៩-៤០)។

៤. នៅក្នុងអំឡុងពេលសវនាការលើការបង្ហាញឯកសារគន្លឹះលើកទីពីរលើអង្គហេតុស្តីពីការដ្ឋានការងារ (“សវនាការលើឯកសារលើកទីពីរ”) ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានជំទាស់នឹងការបង្ហាញកំណត់ហេតុស្តាប់ចម្លើយ ជាពិសេសត្រង់ករណីដែលវាពុំបានបង្ហាញថា សាក្សីបានទទួលមរណភាពរួចហើយ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ១៨-១៩, ២៥-២៦)។ ក្រុមមេធាវីទាំងពីរក្រុមបានសន្និដ្ឋានថា សវនាការលើការបង្ហាញឯកសារគន្លឹះគឺស្រដៀងគ្នាទៅនឹងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ហេតុដូច្នេះ សវនាការទាំងនេះពុំសមស្របធ្វើឡើងនៅក្នុងពេលជំនុំជម្រះនោះឡើយ។ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ១៨-១៩, ២៥-២៦)។ អង្គជំនុំជម្រះបានបដិសេធការជំទាស់ទាំងនេះ។ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ១៩-២០, ២២, ២៥)។

៥. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានគូសបញ្ជាក់សាជាថ្មីថា ភាគីអាចយោងទៅលើឯកសារនានាដែលត្រូវបានសម្រេចទទួលយករួចហើយសម្រាប់សំណុំរឿង ០០២/០២ ហើយទោះបីអង្គជំនុំជម្រះរំពឹងថា ភាគីទំនងជាសំអាងភាគច្រើនលើឯកសារទាំងនោះក៏ដោយ ក៏ភាគីអាចយោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយបានផងដែរ។ អង្គជំនុំជម្រះបានរំលឹកដល់ភាគីនានាថា ភស្តុតាងឯកសារមិនចាំបាច់ត្រូវតែទទួលយកនៅក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សីទេ ហេតុដូច្នេះ សវនាការលើការបង្ហាញឯកសារគន្លឹះបានអនុញ្ញាតឱ្យអង្គជំនុំជម្រះ និង ភាគីអាចបង្ហាញឯកសារទាំងឡាយដែលជាប់ពាក់ព័ន្ធបំផុតទៅនឹងការជំនុំ-

ជម្រះ ហើយនឹងអាចផ្តល់លទ្ធភាពឱ្យសាធារណជនបានយល់ដឹងអំពីឯកសារផ្សេងៗនៅក្នុងការជំនុំជម្រះផងដែរ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា នត្ថិភាពនៃសក្ខីកម្មផ្ទាល់មាត់ និង ឱកាសនៃការសួរតទល់គឺជាកត្តាពាក់ព័ន្ធដែលត្រូវយកមកពិចារណាក្នុងការវាយតម្លៃ និង ទម្ងន់នៃភ័ស្តុតាងដែលត្រូវផ្តល់ឱ្យទៅលើកំណត់ហេតុស្តាប់ចម្លើយ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ (ប្រតិចារឹកសវនាការ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៣៨-៣៩)។

៦. សម្រាប់គោលបំណងនៃសវនាការលើការបង្ហាញឯកសារគន្លឹះនាពេលខាងមុខ អង្គជំនុំជម្រះសូមបញ្ជាក់បំភ្លឺដូចខាងក្រោម៖

ក. អង្គជំនុំជម្រះបញ្ជាក់សាជាថ្មីថា អង្គជំនុំជម្រះមានបំណងឱ្យភាគីផ្តោតលើការបង្ហាញឯកសារទាំងឡាយដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងអង្គហេតុនៃការជំនុំជម្រះ ទោះបីជាភាគីនឹងទទួលបានសិទ្ធិខ្លះក្នុងចាត់ចែងលើរបៀបនៃការប្រើប្រាស់ពេលវេលាដែលបានផ្តល់ឱ្យពួកគេក៏ដោយ។

ខ. ដោយយល់ដឹងអំពីពេលវេលាមានកម្រិតរបស់ភាគីដូចបានលើកឡើងខាងលើ ភាគីអាចជ្រើសរើសបង្ហាញកំណត់ហេតុស្តាប់ចម្លើយ និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។

គ. អង្គជំនុំជម្រះនឹងអនុញ្ញាតផ្តល់ភាពបត់បែនបន្ថែម ហើយនឹងផ្តល់សិទ្ធិឱ្យភាគីបង្ហាញឯកសារទាំងឡាយដែលជាប់ទាក់ទងនឹងគោលនយោបាយនៅក្នុងកម្រិតថ្នាក់ជាតិបាន ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារទាំងនេះទំនងសមស្របជាងសម្រាប់អង្គហេតុនៃការជំនុំជម្រះស្តីពីតួនាទីរបស់ជនជាប់ចោទក៏ដោយ។

ឃ. ទោះបីជាទទួលស្គាល់ថា អង្គជំនុំជម្រះពិបាកនឹងបញ្ចៀសមិនឱ្យលើកឡើងពីការផ្តល់យោបល់លើតម្លៃជាភ័ស្តុតាងនៃឯកសារក៏ដោយ តែអង្គជំនុំជម្រះលើកទឹកចិត្តឱ្យភាគីផ្តោតជាសំខាន់លើការបង្ហាញឯកសារគន្លឹះ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ១៤-១៥)។

ង. ដូចអង្គជំនុំជម្រះបានសម្រេចរួចហើយលើភាពអាចទទួលយកបាននៃឯកសារទាំងអស់ដែលភាគីបានស្នើសុំនាដើមដំបូងនៃការជំនុំជម្រះ មានតែឯកសារដែលបានទទួលស្គាល់ហើយតែប៉ុណ្ណោះដែលអាចយកមកបង្ហាញនៅក្នុងអំឡុងពេលសវនាការទាំងនេះបាន។

ច. ឯកសារដែលបានទទួលមកពីការធ្វើទារុណកម្មត្រូវគោរពតាមសេចក្តីសម្រេចទាំងឡាយពីមុនរបស់អង្គជំនុំជម្រះទៅលើការប្រើប្រាស់ភស្តុតាងបែបនោះ។

***<u>កាលវិភាគនៃសវនាការលើការបង្ហាញឯកសារគន្លឹះលើកទីបី</u>***

៧. អង្គជំនុំជម្រះជូនដំណឹងជាមុនដល់ភាគីថា សវនាការលើការបង្ហាញឯកសារគន្លឹះទាក់ទងនឹងការប្រព្រឹត្តលើក្រុមមនុស្សគោលដៅជាក់លាក់ រួមមានជនជាតិចាម ជនជាតិវៀតណាម និង អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនឹងគ្រោងធ្វើឡើងរយៈពេលបីថ្ងៃ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦។ អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីបង្ហាញឯកសារដែលទាក់ទិននឹងការប្រព្រឹត្តិមកលើអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ បើទោះបីជាអង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ភាគីទទួលបានការអនុញ្ញាតឱ្យបង្ហាញឯកសារទាំងនេះនៅក្នុងសវនាការលើកទីមួយ និង លើកទីពីរហើយក្តី ។ ភាគីក៏នឹងទទួលការអនុញ្ញាតឱ្យធ្វើយ៉ាងដូច្នេះនៅក្នុងសវនាការបង្ហាញឯកសារគន្លឹះអំពីមន្ទីរសន្តិសុខនានាទៀតដែរ (ឯកសារ E315 កថាខណ្ឌ ១៤)។ ភាគីគួរផ្ញើសារអេឡិចត្រូនិចជូនដល់ភាគីទាំងអស់ និង អង្គជំនុំជម្រះទាក់ទងនឹងបញ្ជីឯកសារដែលពួកគេមានចេតនាចង់បង្ហាញ រួមជាមួយនឹងលេខ ERN ពាក់ព័ន្ធនៅក្នុងគ្រប់ភាសាដែលមាន ឱ្យបានត្រឹមម៉ោង ១:៣០ នាទីរសៀល មុនថ្ងៃចាប់ផ្តើមសវនាការ។

៨. ភាគីនីមួយៗមានពីរវគ្គនៃថ្ងៃសវនាការ (កន្លះថ្ងៃ) ក្នុងការបង្ហាញឯកសារទាក់ទងនឹងការប្រព្រឹត្តលើក្រុមទាំងបីនេះ (ពោលគឺ ជនជាតិចាម ជនជាតិវៀតណាម និង អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ) តាមលំដាប់លំដោយដែលភាគីយល់ឃើញថាសមស្រប។ នៅក្នុងថ្ងៃទីបីនៃថ្ងៃសវនាការ ភាគីអាចលើកយោបល់លើឯកសារទាំងឡាយដែលភាគីម្ខាងទៀតបានដាក់បង្ហាញបាន។

៩. ដោយទទួលស្គាល់ថា មិនមែនគ្រប់ភាគីទាំងអស់អាចមានបំណងប្រើប្រាស់ឱកាសនេះទេនោះ អង្គជំនុំជម្រះណែនាំឱ្យភាគីបញ្ជាក់តាមរយៈសារអេឡិចត្រូនិចជូនដល់អង្គជំនុំជម្រះ និង ភាគីផ្សេងទៀតឱ្យបានត្រឹមថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ អំពី (ចំណុចទី១) តើភាគីមានចេតនា

បង្ហាញឯកសារដែរ ឬ ទេ និង (ចំណុចទី២) តើភាគីមានចេតនាផ្ដល់យោបល់លើឯកសារ ដែលភាគីម្ខាងទៀតបានបង្ហាញដែរ ឬ ទេ។